*“ប្រសិនបើលោកអ្នក ឬនរណាម្នាក់*
*ដែលលោកអ្នកស្គាល់ បង្ហាញឲ្យឃើញ*
*នូវសញ្ញានៃល្បែងស៊ីសង...*
***គឺថាមានជំនួយនៅក្បែរៗដៃ”***

SKY CITY

13239 02/20

# តើលោកអ្នកត្រូវការ **ជំនួយ** ឬទេ?

---

## ការប្តូរផ្តាច់របស់យើង ចំពោះអតិថិជនរបស់យើង

---

R20 GAME RESPONSIBLY

SKY CITY

# អ្នកទទួលភ្ញៀវដោយមានការទទួលខុសត្រូវ

នៅSkyCity យើងចាត់ទុកការទទួលខុសត្រូវរបស់យើងក្នុងភាពជាអ្នកទទួលភ្ញៀវយ៉ាងហ្មត់ចត់ជាទីបំផុត៖ សុវត្ថិភាព និងសុខុមាលភាពរបស់អតិថិជនយើង គឺជាអាទិភាពខ្ពស់បំផុត។

សម្រាប់មនុស្សខ្លះ ល្បែងស៊ីសងអាចនាំឲ្យកើតមានការឈឺចាប់ មានរួមទាំងបញ្ហាប្រាក់កាស ការតានតឹងផ្លូវចិត្ត និងការលំបាកកើតមានក្នុងទំនាក់ទំនង។

ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលលោកអ្នកស្គាល់ បង្ហាញឲ្យឃើញនូវសញ្ញានៃល្បែងស៊ីសង...
គឺថាមានជំនួយនៅក្បែរៗដៃ។

# បញ្ហាល្បែងស៊ីសង

ការលេងល្បែងស៊ីសងអាចជាការរីករាយសម្រាប់មនុស្សភាគច្រើន។ ទោះជាយ៉ាងណាក្តី ការមិនចេះទប់ទល់នៃការលេងល្បែងស៊ីសងរបស់គេ អាចកើតមានយ៉ាងឆាប់រហ័ស(ឬតាមពេលកន្លង) ដោយពុំមានការទទួលស្គាល់សញ្ញាព្រមានមុនកាលកំណត់ ដែលអាចនាំឲ្យកើតទៅជាបញ្ហា។

ផលវិបាកអវិជ្ជមាននៃបញ្ហាល្បែងស៊ីសង អាចប៉ះពាល់ដល់អ្នកលេងលែងស៊ីសង គ្រួសារ ឬមិត្តភក្តិរបស់គេ និយោជករបស់គេ និង/ឬសហគមន៍ទូទៅ។

នេះគឺជាការសំខាន់ដែលត្រូវទទួលស្គាល់សញ្ញាព្រមានមុនកាលកំណត់ ដូចជាភាពមានកំហុស ឬការសោកស្តាយបន្ទាប់ពីវគ្គលេងល្បែងស៊ីសង ឬការចំណាយលុយ និង/ឬពេលវេលាដ៏លើសលុប។

លោកអ្នកអាចវាយតម្លៃអាកប្បកិរិយារបស់លោកអ្នកផ្ទាល់ ដោយឆ្លើយនូវសំណួរដូចតទៅនេះដោយស្មោះត្រង់ ផ្អែកទៅលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកអ្នក។

ប្រសិនបើលោកអ្នកឆ្លើយ "បាទ/ចាស៎" ទៅនឹងសំណួរបី ឬច្រើនជាងដូចតទៅនេះ ការលេងល្បែងស៊ីសងប្រហែលជាកំពុងកើតមាន ការប៉ះពាល់មិនល្អមកលើរូបលោកអ្នក ឬនរណាម្នាក់ដែលលោកអ្នកស្គាល់ហើយ៖

- តើការលេងល្បែងស៊ីសងរបស់លោកអ្នក បានបណ្តាលឲ្យកើតមានបញ្ហាប្រាក់កាសសម្រាប់លោកអ្នក ឬគ្រួសាររបស់លោកអ្នកឬទេ?
- ពេលណាលោកអ្នកលេងល្បែងស៊ីសង តើលោកអ្នកបានវិលត្រឡប់ទៅលេងវិញនៅថ្ងៃផ្សេងទៀត ដើម្បីព្យាយាមយកឈ្នះលុយដែលលោកអ្នកបានលេងចាញ់ឬទេ?
- តើលោកអ្នកបានលេងភ្នាល់ ច្រើនជាងចំនួនប្រាក់ដែលលោកអ្នកអាចល្មមនឹងឲ្យលេងចាញ់ឬទេ?
- តើលោកអ្នកត្រូវការលេងល្បែងស៊ីសង ដោយដាក់ប្រាក់ចំនួនយ៉ាងច្រើនដើម្បីឲ្យមានអារម្មណ៍រំភើបដូចគ្នាឬទេ?
- តើលោកអ្នកបានខ្ចីប្រាក់ ឬលក់វត្ថុទាំងឡាយដើម្បីយកលុយទៅលេងល្បែងស៊ីសងឬទេ?
- តើលោកអ្នកមានអារម្មណ៍ថា លោកអ្នកប្រហែលជាមានបញ្ហាល្បែងស៊ីសងឬទេ?
- តើល្បែងស៊ីសងបានបណ្តាលឲ្យលោកអ្នកកើតមានបញ្ហាសុខភាពណាមួយ មានរួមទាំងភាពតានតឹងក្នុងចិត្ត ឬការថប់បារម្ភឬទេ?
- តើមានមនុស្សរិះគន់អំពីការលេងល្បែងស៊ីសងរបស់លោកអ្នកឬទេ ឬនិយាយប្រាប់លោកអ្នកថា លោកអ្នកមានបញ្ហាល្បែងស៊ីសង ទោះថាលោកអ្នកយល់ឃើញថាវាពុំពិតក្តី?
- តើលោកអ្នកមានអារម្មណ៍ថាមានកំហុស អំពីវិធីដែលលោកអ្នកលេងល្បែងស៊ីសង ឬអ្វីដែលកើតមានឡើង ពេលណាលោកអ្នកលេងល្បែងស៊ីសងឬទេ?

ប្រសិនបើលោកអ្នកចង់និយាយទៅកាន់នរណាម្នាក់ អំពីការលេងល្បែងស៊ីសងរបស់លោកអ្នក ឬអំពីការលេងល្បែងស៊ីសងរបស់នរណាម្នាក់ដែលលោកអ្នកស្គាល់ លោកអ្នកអាចទូរស័ព្ទទៅខ្សែទូរស័ព្ទជំនួយបញ្ហាល្បែងស៊ីសង (Gambling Helpline) - លេខ 0800 654 655 (ឥតគិតថ្លៃ ហើយរក្សាទុកជាសម្ងាត់ ធ្វើការ២៤ម៉ោង) ឬបើកមើលវិបសាយ www.gamblinghelpline.co.nz

*ផ្ញើសារ* **8006** *ឬ*
*ហៅ ខ្សែទូរស័ព្ទជំនួយបញ្ហាល្បែងស៊ីសង*
**0800 654 655**
*(ឥតគិតថ្លៃ ហើយរក្សាទុកជាសម្ងាត់ ធ្វើការ២៤ម៉ោង)*

# ការពិគ្រោះយោបល់

វគ្គពិគ្រោះយោបល់គឺជាការពិភាក្សាជាមួយបុគ្គលម្នាក់ ដើម្បីនិយាយអំពីកិច្ចការទាំងឡាយដែលជាកង្វល់ចំពោះលោកអ្នក – ជាពិសេសបញ្ហាល្បែងស៊ីសង។ ការធ្វើការជាមួយអ្នកពិគ្រោះយោបល់ ពុំមែនអំពីការធ្វើអ្វីៗតាមតែគេប្រាប់នោះទេ – នេះគឺជាវិធីស្វែងរកយុទ្ធសាស្ត្រ និងដំណោះស្រាយទាំងឡាយដែលត្រឹមត្រូវសម្រាប់លោកអ្នក។

ការពិគ្រោះយោបល់អំពីបញ្ហាល្បែងស៊ីសង ផ្តល់ជូនដោយឥតគិតថ្លៃ ហើយតាមមូលដ្ឋានលាក់ការសម្ងាត់ ដោយអង្គការដូចមានចុះខាងក្រោមនេះ។

**The Salvation Army Addiction Services – Gambling** 0800 530 000
(កិច្ចបំរើការញៀន **Salvation Army** - ល្បែងស៊ីសង)

**Problem Gambling Foundation** (មូលនិធិបញ្ហាល្បែងស៊ីសង) 0800 664 262

**Asian Family Services** (កិច្ចបំរើគ្រួសារអាស៊ី) 0800 862 342

**Pasifika Gambling Helpline** 0800 654 657
(ខ្សែទូរស័ព្ទជំនួយបញ្ហាល្បែងស៊ីសងសម្រាប់ជនជាតិ **Pasifika**)

**Maori Gambling Helpline** 0800 654 656
(ខ្សែទូរស័ព្ទជំនួយបញ្ហាល្បែងស៊ីសងសម្រាប់ជនជាតិ **Maori**)

**Community Alcohol and Drug Service** 09 845 1818
(កិច្ចបំរើជំនួយបញ្ហាសុរា និងគ្រឿងញៀនសហគមន៍)

**Hapai Te Hauora Tapui** 09 520 4796

**Tupu Pacific Mental Health Service** 09 845 1810
(កិច្ចបំរើសុខភាពផ្លូវចិត្តសម្រាប់ជនជាតិ **Tupu Pacific**)

**Raukura Hauora o Tainui** 09 263 8040

# ការដកខ្លួនឯងចេញពីកន្លែងលេងល្បែងស៊ីសង

បន្ថែមពីលើការជួយមកពីអង្គការពិគ្រោះយោបល់ លោកអ្នក ឬនរណាម្នាក់ដែលលោកអ្នកស្គាល់ ប្រហែលជាប្រាថ្នាចង់រួមចំណែកក្នុងកម្មវិធីដកខ្លួនឯងចេញពីកន្លែងលេងល្បែងស៊ីសងរបស់ SkyCity។

នៅក្រោមកម្មវិធីនេះ អតិថិជនអាចស្នើសុំឲ្យគេហាមឃាត់ខ្លួនដោយស្ម័គ្រចិត្ត មិនឲ្យចូលទីកន្លែងកាស៊ីណូ SkyCity ទាំងអស់នៅក្នុងប្រទេសញូវហ្សេឡែន។ សូមអានកូនសៀវភៅ 'ការដកខ្លួនឯងចេញពីកន្លែងលេងល្បែងស៊ីសង' របស់ SkyCity ដើម្បីឲ្យបានយល់ដឹងច្រើន។

**SKYCITY AUCKLAND** 0800 SKYCITY (0800 759 2489)

**SKYCITY HAMILTON** 07 834 4900

**SKYCITY QUEENSTOWN** 03 441 0400

**ការទទួលភ្ញៀវដោយមានការទទួលខុសត្រូវរបស់ SkyCity**
**អ៊ីម៉េល:** hostresponsibility@skycity.co.nz